ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ [illegible] អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូមេមត់

## រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ ជស/រកម/ ០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពី ការអនុវត្តន៍ព្រះរាជក្រម ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ២០០៣ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអភិវឌ្ឍនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និងក្រុមហ៊ុនជលផល

-បានឃើញកិច្ចសន្យាទិញ-លក់ និង កិច្ចសន្យាជួលដី ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៨ រវាងរាជរដ្ឋាភិបាលកម្ពុជា និង ក្រុមហ៊ុន ធីធីវ៉ាយ អភិវឌ្ឍន៍ដំណាំ កសិកម្ម និង អាហារ៉ែណ នីហារ៉ែណ

-តាមសំណើរបស់គណៈកម្មាធិការជាតិអភិវឌ្ឍនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និង ក្រុមហ៊ុនជលផល

## សម្រេច

**មាត្រា ១ :** បញ្ឈប់ស្ថានភាពគតិយុត្តិចំការកៅស៊ូមេមត់ដែលជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ចាប់ពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ តទៅ ។

**មាត្រា ២:** ផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូមេមត់ ទៅឱ្យក្រុមហ៊ុន ធីធីវ៉ាយ អភិវឌ្ឍន៍ដំណាំ កសិកម្ម និង នាំចេញ នាំចូល (TTY Agricultural Plant Development & IMEX Co., Ltd.) ដើម្បីបន្តគ្រប់គ្រងស្របតាមបទប្បញ្ញត្តិនានាដែលបានកំណត់ក្នុងកិច្ចសន្យាទិញ-លក់ និង កិច្ចសន្យាជួលដី ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៨ រវាងរាជរដ្ឋាភិបាលកម្ពុជា និង ក្រុមហ៊ុន ធីធីវ៉ាយ អភិវឌ្ឍន៍ដំណាំ កសិកម្ម និង នាំចេញ នាំចូល (TTY Agricultural Plant Development & IMEX Co., Ltd.) ចាប់ពីថ្ងៃ ទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ តទៅ ។

**មាត្រា ៣:** រំលាយក្រុមប្រឹក្សាភិបាលប្រចាំចំការកៅស៊ូមេមត់ ដែលត្រូវបានតែងតាំងដោយអនុក្រឹត្យលេខ ៨៥១ អនក្រ-តត ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៥ ត្រង់ ចំណុច ក នៃមាត្រា១ រំលាយប្រធានអគ្គនាយកចំការកៅស៊ូមេមត់ និង រំលាយមន្ត្រីត្រួតពិនិត្យរដ្ឋអមចំការកៅស៊ូមេមត់ ចាប់ពីថ្ងៃ ទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ តទៅ ។

**មាត្រា ៤ :** ផ្ទេរឯកឧត្តម ណោ ម៉ារ៉ាឌី ប្រធានអគ្គនាយកចំការកៅស៊ូមេមត់ ចូលមកបំពេញការងារក្នុងក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទវិញ ចាប់ពីថ្ងៃ ទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ តទៅ ។

**មាត្រា ៥:** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទត្រូវទទួលបន្ទុកដោះស្រាយបន្ត រាល់បំណុលត្រូវទារ និង ត្រូវសង ដែលនៅសេសសល់ទាំងអស់រវាងចំការកៅស៊ូមេមត់ និង បណ្តាក្រុមហ៊ុន ស្ថាប័ននានានិងអតិថិជន និង បន្តស្រាវជ្រាវ និង ប្រមូលចំណូលបានពីការកាប់ដើមកៅស៊ូចាស់ៗដែលមិនត្រូវបានយកទៅប្រើប្រាស់សំរាប់ការដាំដុះឡើងវិញ ដើម្បីបង់ចូលថវិការដ្ឋ ។

**មាត្រា ៦:** ចំការកៅស៊ូមេមត់ត្រូវប្រគល់ត្រា និង ឯកសារពាក់ព័ន្ធទាំងអស់ រួមទាំងឯកសារក្នុងកុំព្យូទ័រ មកក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីរក្សាទុក ។

**មាត្រា ៧:** ថវិកាដែលនៅសល់ក្នុងគណនី និង បេឡា របស់ចំការកៅស៊ូមេមត់ ត្រូវផ្ទេរចូលថវិការដ្ឋ ។ បិទរាល់គណនីធនាគារទាំងអស់របស់ចំការកៅស៊ូមេមត់ចាប់ពីថ្ងៃ ទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ តទៅ ។

**មាត្រា ៨:** អនុក្រឹត្យលេខ ១៣ អនក្រ-បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពី ការបង្កើតចំការកៅស៊ូមេមត់ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ចាប់ពីថ្ងៃ ទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ តទៅ ។

**មាត្រា ៩:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- ឯកសារ-កាលប្បវត្តិ